# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៩ ស.សរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន (AEM) លើកទី៣៥ និងកិច្ចប្រជុំពាក់ព័ន្ធ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## <u>សំ រេ ច</u>

**ប្រការ១:** បង្កើតគណៈកម្មការរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន (AEM) លើកទី៣៥ និងកិច្ចប្រជុំពាក់ព័ន្ធ ដែលនឹងប្រព្រឹត្តិទៅ ចាប់ពីថ្ងៃទី៣០ ខែសីហា ដល់ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៣ នៅរាជធានីភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១- ឯកឧត្តម **ចម ប្រសិទ្ធ** | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន | ប្រធាន |

| | | |
|---|---|---|
| ២- ឯកឧត្តម អ៊ុក រ៉ាប៊ុន | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម ហុក ឡុងឌី | អគ្គស្នងការនគរបាលជាតិក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- ឯកឧត្តម មិន មាន | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការ អចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ | អនុប្រធាន |
| ៥- ឯកឧត្តម ខៀវ កាញារីទ្ធ | រដ្ឋលេខាធិការក្រសួងពត៌មាន | សមាជិក |
| ៦- ឯកឧត្តម កែប ជុតិមា | អភិបាលរាជធានីភ្នំពេញ | សមាជិក |
| ៧- ឯកឧត្តម គីម ស៊ីថន | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៨- ឯកឧត្តម ម៉ែម ទិត្យា | អគ្គលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៩- ឯ.ឧ.ឧត្តមសេនីយឯក នាង ផាត | អគ្គនាយកក្រសួងការពារជាតិ | សមាជិក |
| ១០- ឯ.ឧ.ឧត្តមសេនីយឯក សៅ សុខា | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១១- ឯកឧត្តម ម៉ៅ ថូរ៉ា | អគ្គនាយកបច្ចេកទេសក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១២- លោក ពេជ ម្ចន្ទី | អគ្គនាយករងបច្ចេកទេសក្រសួងពាណិជ្ជកម្ម និងជាឧត្តមមន្ត្រី សេដ្ឋកិច្ចអាស៊ានកម្ពុជា | សមាជិក |

**ប្រការ២ :** គណៈកម្មការរៀបចំកិច្ចប្រជុំនេះមានភារកិច្ចដូចតទៅ :

ក- រៀបចំកម្មវិធីប្រជុំ និងពិធីការអោយបានសមស្រប

ខ- រៀបចំគំរោងចំណាយសំរាប់រៀបចំកិច្ចប្រជុំខាងលើ រួចលើកសំណើសុំថវិកាពីរាជរដ្ឋាភិបាល

គ- សំរបសំរួល រៀបចំការពារសន្តិសុខជូនគណៈប្រតិភូ និងសមាជិកអង្គប្រជុំអោយមានសុវត្ថិភាពល្អ

ឃ- ចាត់ចែងការសំដែងសិល្បៈប្រពៃណី ជូនគណៈប្រតិភូក្នុងក្របខ័ណ្ឌជាតិ និងភាគរៈអន្តរជាតិ

ង- សំរបសំរួល និងចាត់ចែងការធ្វើដំណើរទស្សនាចរជូនគណៈប្រតិភូ ក្រោយកិច្ចប្រជុំ តាមកម្មវិធីដែលបានគ្រោងទុក

ច- សំរបសំរួលជាមួយប្រព័ន្ធឃោសនាជាតិ និងអន្តរជាតិ ដើម្បីធ្វើការផ្សព្វផ្សាយពីកិច្ចប្រជុំនេះ ។

**ប្រការ៣ :** ប្រធានគណៈកម្មការរៀបចំកិច្ចប្រជុំនេះ មានសិទ្ធិអញ្ជើញមន្ត្រីជំនាញនៃក្រសួង-ស្ថាប័នពាក់ព័ន្ធនានា មកចូលរួមប្រជុំ ដើម្បីពិភាក្សា និងដោះស្រាយការងារដែលចាំបាច់ ។

**ប្រការ៤ :** ប្រធានគណៈកម្មការនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការជំនាញផ្សេងទៀត តាមការចាំបាច់ ។

**ប្រការ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងពតិមាន អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ អភិបាលរាជធានីភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង និងស្ថាប័នពាក់ព័ន្ធ ឯកឧត្តម និងលោក ដែលមានឈ្មោះក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ១ និងប្រការ៥
- ឯកសារ-កាលប្បវត្តិ